ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៧៥ សហវ.....

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារ សម្រាប់កិច្ចប្រជុំ «ច្រកចេញ - ចូលតែមួយ» និង កិច្ចប្រជុំយន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សអភិវឌ្ឍន៍កម្ពុជា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង
- អនុក្រឹត្យលេខ ៧៨ អនក្រ. បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង ការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** បង្កើតក្រុមការងារសម្រាប់កិច្ចប្រជុំ «ច្រកចេញ- ចូលតែមួយ» និង កិច្ចប្រជុំយន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១. ឯកឧត្តម **ហង់ ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោក **អ៊ុយ សារិន** | តំណាងទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៤. លោក **ស្រី ចន្ណា** | តំណាងនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥. លោក **ម៉ឹង បុណ្ណារិទ្ធ** | តំណាងនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៦. លោក **អេង ឆ្មួច** | តំណាងនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | សមាជិក |
| ៧. លោក **ខួន មាស** | ជំនួយការអគ្គលេខាធិការ | លេខាធិការ |
| ៨. លោក **ម៉ៅ បុរាណា** | ជំនួយការអគ្គលេខាធិការរង | លេខាធិការ |

**ប្រការ ២:** ក្រុមការងារនេះ មានភារកិច្ចដូចតទៅ:

- ពិនិត្យរាល់ឯកសារពាក់ព័ន្ធការងាររបស់អង្គប្រជុំ «ច្រកចេញ- ចូលតែមួយ» និង អង្គប្រជុំប្រហាក់ប្រហែលតាមការចាំបាច់ និង ការងារដែលត្រូវបំពេញ ដើម្បីដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សម្រេច ។
- តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមការងារចាត់ចែង និង ស្នើសុំយោបល់ចូលរួមប្រជុំរបស់ «ច្រកចេញ- ចូលតែមួយ» និង កិច្ចប្រជុំប្រហាក់ប្រហែល ផ្អែកលើតម្រូវការរបស់ក្រុមការងារ និង តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- ផ្តល់អនុសាសន៍ស្តីពីតម្រូវការជាក់ស្តែង និង ការងារជឿនលឿនថ្មីៗ ពាក់ព័ន្ធកិច្ចប្រជុំ «ច្រកចេញ- ចូលតែមួយ» និង អង្គប្រជុំប្រហាក់ប្រហែល ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សម្រេច ។
- ផ្តួចផ្តើមគំនិតរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងភារកិច្ច ដើម្បីធានាប្រសិទ្ធភាពក្រុមការងារ ក៏ដូចជារបស់ក្រសួង ។
- ធ្វើរបាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពីលទ្ធផលការងារ ដែលសម្រេចបានមួយឆមាសម្តង ។

**ប្រការ ៣:** ប្រធានក្រុមការងារនេះ ទទួលខុសត្រូវដឹកនាំការងាររួមរបស់ក្រុមការងារ ។ តាមការចាត់តាំង ឬ ក្នុងករណី

ប្រធានអវត្តមាន អនុប្រធានអចិន្ត្រៃយ៍ដឹកនាំការងារជំនួស ។ សមាសភាពក្រុមការងារត្រូវចូលរួមប្រជុំ តាមការអញ្ជើញ ក្នុងករណីអវត្តមាន អាចចាត់តំណាងរបស់ខ្លួនចូលរួមប្រជុំជំនួស ។ តំណាងដែលត្រូវបានចាត់ឱ្យចូលរួមជំនួស ត្រូវមានជំនាញពាក់ព័ន្ធការងារប្រជុំរបស់ «ច្រកចេញ-ចូលតែមួយ» និង មានសិទ្ធសម្រេចក្នុងនាមនាយកដ្ឋាន-អង្គភាពរបស់ខ្លួន ។ ក្រុមការងារ អាចអញ្ជើញមន្ត្រីពាក់ព័ន្ធនឹងការងាររបស់ខ្លួន ឱ្យចូលរួមប្រជុំបានតាមតម្រូវការជាក់ស្តែង ។

**ប្រការ ៤:** សមាសភាពក្រុមការងារ ដែលបានចូលរួមក្នុងកិច្ចប្រជុំនានា ដែលពាក់ព័ន្ធការងារ «ច្រកចេញ-ចូលតែមួយ» នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ កិច្ចប្រជុំប្រហាក់ប្រហែល ត្រូវរាយការណ៍ជូនក្រុមការងារពីលទ្ធផលនៃកិច្ចប្រជុំនោះ សម្រាប់ជាព័ត៌មាន និង ការតាមដាន សម្រាប់អង្គប្រជុំថ្ងៃមុខទៀត ។

**ប្រការ ៥:** លេខាធិការនៃក្រុមការងារ ត្រូវចូលរួមក្នុងកិច្ចប្រជុំ «ច្រកចេញ-ចូលតែមួយ» នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំ និង ស្រាវជ្រាវរកគ្រប់ឯកសារពាក់ព័ន្ធកិច្ចប្រជុំជូនក្រុមការងារឱ្យបានទៀងទាត់ ។

**ប្រការ ៦:** ប្រកាស ឬ សេចក្តីសម្រេច ដែលមានលក្ខណៈផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**គាត ឈន់**

*កន្លែងទទួល:*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
  *«ដើម្បីជូនជ្រាប»*
- *ដូចប្រការ ៧*
- *ឯកសារ-កាលប្បវត្តិ*